# ស្ថានភាពអតិផរណានៅខែមេសា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែមេសានេះ បានកើនឡើង **0,៥%** ធៀបនឹងខែមុន និង **២,៤%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងខែមេសា សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើនមានការកើនឡើងគួរកត់សម្គាល់ធៀបនឹងខែមីនា កន្លងទៅ។ *តាមការសង្កេតជាទូទៅ ទំនិញភាគច្រើនតែងតែមានការឡើងថ្លៃនៅក្នុងអំឡុងពេលខែមេសា ដោយសារការកើនឡើងតម្រូវការប្រើប្រាស់នាពេលប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ។*

បើធៀបនឹងខែមេសា ឆ្នាំ២០១៧ កន្លងទៅ, សន្ទស្សន៍ថ្លៃទំនិញភាគច្រើនក៏មានការកើនឡើងដូចគ្នាដែរ ក្នុងនោះមានដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង, សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈដទៃទៀត, សន្ទស្សន៍ថ្លៃការដឹកជញ្ជូន និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន។ ទោះបីជាសន្ទស្សន៍ថ្លៃទំនិញមាននិន្នាការកើនឡើង, ប៉ុន្តែ យើងសង្កេតឃើញថា កំណើនថ្លៃទំនិញជាមធ្យមក្នុងរយៈពេល៤ខែដើមឆ្នាំ២០១៨នេះ នៅតែមានកម្រិតទាបជាងអត្រាកំណើនជាមធ្យមក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារការរក្សាបានកំណើនទាបនៃសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ដែលជាមធ្យមមានកំណើនត្រឹមតែ ២,0% ពោលគឺទាបជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៧ (ដែលមានអត្រាកំណើនជាមធ្យម ៥,៤%)។

*យោងតាមបរិការណ៍បច្ចុប្បន្ននេះ យើងអាចធ្វើការសន្និដ្ឋានបានថាស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៨នេះ នៅតែរក្សាបានស្ថិរភាពល្អ គឺក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ដោយសារនិន្នាការថមថយកំណើនសន្ទស្សន៍ថ្លៃក្រុមទំនិញម្ហូបអាហារ, បើទោះបីជាថ្លៃប្រេងឥន្ទនៈមាននិន្នាការងើបឡើងវិញបន្តិចក៏ដោយ។*

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | **ធៀបនឹងខែមុន** | **ធៀបនឹង១ឆ្នាំមុន** |
| **មុខទំនិញគ្រប់មុខ** | **+0,៥** | **+២,៤** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +0,៧ | +២,៣ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +១,៦ | +0,៩ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +0,៤ | +១,៣ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +0,១ | +១,៣ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +0,៣ | -0,២ |
| ៦-សុខាភិបាល | +0,៣ | +១,៨ |
| ៧-ការដឹកជញ្ជូន | +0,៥ | +៣,0 |
| ៨-គមនាគមន៍ | +0,១ | -១,0 |
| ៩-ការកំសាន្ត និងវប្បធម៌ | +0,២ | -0,៨ |
| ១0-ការសិក្សា | +0,៤ | -0,៤ |
| ១១-ភោជនីយដ្ឋាន | 0,0 | +៦,៧ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +0,៥ | +៣,៦ |

| តារាង ២ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | កុម្ភៈ | មីនា | មេសា | កុម្ភៈ | មីនា | មេសា |
| អង្ករ | +០,២ | +០,២ | +០,១ | +២,១ | +២,២ | +២,៣ |
| សាច់គោ | +០,៧ | -០,១ | +០,៧ | +២,៨ | +២,៨ | +៣,៥ |
| សាច់មាន់ | +១,១ | -០,៨ | +១,០ | +០,៥ | +០,៦ | +១,០ |
| សាច់ទា | -០,២ | -០,១ | +០,៥ | +០,៩ | +០,៦ | +១,៤ |
| សាច់ជ្រូក | +០,៣ | +០,៥ | +០,៥ | +០,៣ | +០,៧ | +០,២ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,៣ | +០,២ | +០,៦ | +៤,១ | +៤,៥ | +៤,០ |
| ក្នុងនោះត្រីស្រស់ | +០,៣ | +០,២ | +០,៦ | +៤,៤ | +៤,៨ | +៤,៣ |
| ផ្លែឈើ | +១,៧ | ០,០ | +១,៧ | +១,៧ | +១,៣ | +៣,៥ |
| ផ្លែឈើស្រស់ | +១,៨ | -០,១ | +២,០ | +០,៩ | +០,៣ | +២,៧ |
| បន្លែ | +០,៣ | +០,៣ | +១,៣ | -០,៥ | +០,៧ | +០,៩ |
| បន្លែជាស្លឹក | +០,១ | +០,៩ | +១,៤ | -០,៩ | +១,៨ | +១,៨ |
| បន្លែជាផ្លែ | +០,៧ | +០,៥ | +១,៨ | -១,៦ | -០,៣ | +០,៥ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | | ២០១៨ | | | |
| | មករា | កុម្ភៈ | មីនា | មេសា | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | 4.4 | 4.0 | 4.3 | 3.2 | 2.0 | 2.3 | 2.3 | 2.4 |
| ប្រទេសវៀតណាម | 5.2 | 5.0 | 4.7 | 4.3 | 2.7 | 3.2 | 2.7 | 2.8 |
| ប្រទេសថៃ | 1.6 | 1.4 | 0.76 | 0.4 | 0.68 | 0.42 | 0.79 | 1.07 |
| ប្រទេសម៉ាឡេស៊ី | 3.2 | 4.5 | 5.1 | 4.4 | 2.7 | 1.4 | 1.3 | 1.4 |
| ប្រទេសឥណ្ឌូនេស៊ី | 3.5 | 3.8 | 3.6 | 4.2 | 3.3 | 3.2 | 3.4 | 3.4 |
| ប្រទេសហ្វីលីពីន | 2.7 | 3.3 | 3.1 | 3.2 | 4.0 | 3.9 | 4.3 | 4.5 |
| ប្រទេសចិន | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 2.9 | 2.1 | 1.8 |
| ប្រទេសកូរ៉េខាងត្បូង | 2.0 | 1.9 | 2.2 | 1.9 | 1.0 | 1.4 | 1.3 | 1.6 |
| ប្រទេសជប៉ុន | 0.4 | 0.3 | 0.2 | 0.4 | 1.4 | 1.5 | 1.1 | 0.6 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។ ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*